# <u>ការផ្លាស់ប្តូរសំខាន់ចំពោះគោលការណ៍លុបថ្ងៃសិក្សានៅសាលា</u>

ថ្ងៃទី 14 ខែ ធ្នូ ឆ្នាំ 2020

គោរពជូនក្រុមគ្រួសារសង្កាត់សាលា Lowell Public Schools ទាំងអស់៖

ដោយសារអាកាសធាតុក្នុងរដូវរងារខ្លះត្រូវបានគេព្យាករណ៍ថានឹងកើតមានឡើងនៅចុងសប្តាហ៍នេះ យើងចង់ទាក់ទងសហគមន៍ LPS របស់យើងដើម្បីចែករំលែកជាមួយលោកអ្នកនូវការផ្លាស់ប្តូរនៅក្នុងគោលការណ៍លុបចោលថ្ងៃសិក្សានៅសាលារបស់យើងសម្រាប់ឆ្នាំសិក្សានេះ។

កាលពីមុន ប្រសិនបើមានអាកាសធាតុមិនល្អ យើងមានជម្រើសក្នុងការពន្យាពេលនៃថ្ងៃបើកបវេសនកាល ឬ លុបចោលថ្ងៃសិក្សានៅសាលា និងជម្រើសផ្អាកសាលារៀនសិននៅ “ថ្ងៃធ្លាក់ព្រិល”។ គណៈកម្មការសាលាថ្មីៗនេះបានអនុម័តបន្ថែមជម្រើសទីបីគឺ “ថ្ងៃរៀនសូត្រពីចម្ងាយពេញលេញ” ទៅនឹងគោលការណ៍ដែលមានស្រាប់នេះរហូតដល់ថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2021 ។

ជម្រើសថ្មីនេះផ្តល់ជូនយើងនូវភាពអាចបត់បែនតាមកាលៈទេសៈបន្ថែមថែមទៀត។ ជំនួសឲ្យការផ្អាកសាលារៀននៅថ្ងៃធ្លាក់ព្រិលតាមទម្លាប់ ប្រសិនបើអគារសាលារៀនរបស់យើងត្រូវបានបិទដោយសារអាកាសធាតុរដូវរងារនោះ ឥឡូវនេះយើងអាចមានថ្ងៃសិក្សាពីចម្ងាយ ដែលនឹងត្រូវបានបញ្ចូលទៅក្នុងចំនួនថ្ងៃសិក្សាដែលបានតម្រូវទុក។

សេចក្តីសម្រេចក្នុងការមានថ្ងៃសិក្សាពីចម្ងាយពេញលេញនឹងមានឥទ្ធិលដល់សិស្សគ្រប់គ្នា ដោយមិនគិតដល់ថាតើពួកគេចូលរៀនសាលារៀនដោយផ្ទាល់ ឬ ពីចម្ងាយជាប្រចាំឬអត់នោះទេ។ អគារសាលារៀននឹងត្រូវបានបិទនៅថ្ងៃសិក្សាពីចម្ងាយពេញលេញ ហើយការរៀនសូត្រនឹងត្រូវធ្វើឡើងចេញពីផ្ទះសម្រាប់សិស្សគ្រប់គ្នា។ បុគ្គលិកសាលានឹងផ្តល់ឲ្យសិស្សនូវព័ត៌មានបន្ថែមទៀតទាក់ទងនឹងការរំពឹងទុកនៃការសិក្សានេះសម្រាប់ថ្ងៃសិក្សាពីចម្ងាយពេញលេញដោយសារអាកាសធាតុមិនល្អ។

នៅពេលអគារសាលារៀនត្រូវបានបិទដោយសារអាកាសធាតុមិនល្អ ដែលរួមមានថ្ងៃសិក្សាពីចម្ងាយពេញលេញ កន្លែងដែលត្រូវទៅយកអាហារក៏នឹងត្រូវបានបិទផងដែរ។ ប៉ុន្តែ នៅក្នុងករណីយើងអាចរំពឹងទុកបានថាអាចនឹងមានព្យុះនោះ សិស្សនឹងអាចទទួលបានអាហារបន្ថែមនៅកន្លែងដែលត្រូវទៅយកអាហារមួយថ្ងៃមុន។ យើងនឹងទាក់ទងបញ្ហានេះជាមួយគ្រួសារជាមុន។

យើងនឹងប្រកាសពីថ្ងៃសិក្សាពីចម្ងាយពេញលេញ គ្មានថ្ងៃសិក្សានៅសាលា ឬ ការពន្យាពេលក្នុងការបើកបវេសនកាលតាមទូរស័ព្ទ អ៊ីមែល គេហទំព័រ LPS និងតាមបណ្តាញផ្សព្វផ្សាយសង្គម LPS ។ យើងក៏នឹងចែករំលែកព័ត៌មាននេះជាមួយស្ថានីយ៍វិទ្យុ និង ទូរទស្សន៍ក្នុងតំបន់ផងដែរ។

សូមអរគុណសម្រាប់ការបន្តការគាំទ្រនិងភាពជាដៃគូរបស់លោកអ្នកពេញមួយឆ្នាំសិក្សានេះ។